ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើនបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ, ក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី៣ និង ក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី ២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

៣៚៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/១២០ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ របស់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល, ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេសរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកែប្រែ តម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

www.pheakdeylaw.com

## សម្រេច

**មាត្រា១** : អនុក្រឹត្យនេះ មានគោលដៅបង្កើនបៀវត្សរ៍មូលដ្ឋានប្រចាំខែកម្រិតទាបបំផុតរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ ,ក្របខ័ណ្ឌ គ ឋានន្តរស័ក្តិទី ៣ និងក្របខ័ណ្ឌ គ ឋានន្តរ-ស័ក្តិទី ២ ក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យដល់កម្រិត ៣២០ ០០០ រៀល ។

**មាត្រា ២** : ការបង្កើនបៀវត្សរ៍មូលដ្ឋាន ដូចមានចែងក្នុងមាត្រា ១ ខាងលើនេះ ត្រូវចាប់ផ្តើមអនុវត្តពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៣ តទៅ ។ ដោយឡែក ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងទៀត ដែលកំពុងស្ថិតនៅជាធរមានសម្រាប់មន្ត្រីរាជការនៃក្របខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ១ ខាងលើ នឹងត្រូវបន្តអនុវត្តតទៅទៀត ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋ-លេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថ-លេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *កាលប្បវត្តិ*

www.pheakdeylaw.com